クメール語

(ថ្ងៃទី10 ខែកុម្ភៈ ឆ្នាំ2022)

ひと、くらし、みらいのために
厚生労働省
Ministry of Health, Labour and Welfare

សម្រាប់កុមារអាយុ 5-11 ឆ្នាំ
និងអាណាព្យាបាល

# សេចក្តីជូនដំណឹងអំពីការចាក់វ៉ាក់សាំងការពារកូវីដ-19



ថ្លៃចាក់
ឥតគិតថ្លៃ
(ចំណាយរបស់រដ្ឋទាំងស្រុង)

## កុមារអាយុចាប់ពី ៥ ឆ្នាំឡើងក៏អាចទទួលការចាក់វ៉ាក់សាំងកូវីដ-19 បានដែរ។

សូមអានសេចក្តីពន្យល់នេះជាមួយអ្នកផ្ទះ ហើយពិភាក្សាថាចាក់វ៉ាក់សាំងឬទេ។

**នៅថ្ងៃចាក់វ៉ាក់សាំង សូមភ្ជាប់មកជាមួយសៀវភៅសុខភាពមាតានិងទារក។**

**បច្ចុប្បន្នកុមារដែលមានអាយុចាប់ពី៥-១១ឆ្នាំ ក៏អាចទទួលបានការចាក់វ៉ាក់សាំងផងដែរ។ ក្នុងចំណោមអ្នកឆ្លងកូវីដ-19សរុបក្នុងប្រទេស ចំនួនកុមារឆ្លងមានការកើនឡើង។ សូមអានសេចក្តីពន្យល់ ហើយពិចារណាជាមួយកូនៗរបស់អ្នកអំពីការចាក់វ៉ាក់សាំងនេះ។**

## ◎វ៉ាក់សាំងដែលប្រើ

វ៉ាក់សាំងក្រុមហ៊ុនPfizer សម្រាប់មនុស្សអាយុ 5–11ឆ្នាំ។ វាជាវ៉ាក់សាំងសម្រាប់កុមារ (*) ។
ជាធម្មតា សរុបត្រូវ**ចាក់ 2 លើក**ដោយទុកគម្លាត **3 សប្តាហ៍**។

(*) បើធៀបនឹងវ៉ាក់សាំងសម្រាប់អាយុ 12 ឆ្នាំឡើងរបស់ក្រុមហ៊ុនPfizer វាមានសារធាតុផ្សំសកម្មស្មើនឹង1/3។

## ◎ក្រុមគោលដៅសម្រាប់ចាក់វ៉ាក់សាំងនេះ

- អ្នកមានអាយុពី 5–11 ឆ្នាំ
- លើកទឹកចិត្តចំពោះកុមារដែលមានជម្ងឺប្រចាំកាយ ដូចជាជម្ងឺប្រដាប់ដង្ហើមរ៉ាំរ៉ៃ និងជម្ងឺបេះដូងពីកំណើតជាដើម ដែលមានហានិភ័យខ្ពស់ អាចវិវត្តទៅកម្រិតធ្ងន់ធ្ងរ (*)។ សូមពិគ្រោះឲ្យបានត្រឹមត្រូវជាមួយគ្រូពេទ្យប្រចាំខ្លួនជាមុន មុននឹងទទួលការចាក់វ៉ាក់សាំង។

(*) (*) សមាគមវេជ្ជសាស្ត្រផ្នែកកុមារជប៉ុន មានបោះពុម្ពផ្សាយបញ្ជីរាយនាមជំងឺដែលមានហានិភ័យខ្ពស់ ដែលអាចវិវត្តជាធ្ងន់ធ្ងរ នៅពេលឆ្លងជម្ងឺកូវីដ-១៩។
សមាគមវេជ្ជសាស្ត្រផ្នែកកុមារជប៉ុន "ព័ត៌មានពាក់ព័ន្ធនឹងកូវីដ-19"
URL : https://www.jpeds.or.jp/modules/activity/index.php?content_id=333

## ប្រសិទ្ធភាពនៃវ៉ាក់សាំងកូវីដ-19

### Q. តើវ៉ាក់សាំងកូវីដ-19 មានប្រសិទ្ធភាពបែបណា?

**A. តាមរយៈការចាក់វ៉ាក់សាំងកូវីដ-19 ទោះបីឆ្លងកូវីដ-19ក៏ដោយក៏មិនងាយនឹងចេញរោគសញ្ញាដែរ។**

នៅពេលចាក់វ៉ាក់សាំង នៅក្នុងរាងកាយនឹងបង្កើតប្រព័ន្ធ(ភាពស៊ាំ)ប្រឆាំងនឹងកូវីដ-19។ ពេលវីរុសឆ្លងចូលក្នុងរាងកាយខ្លួនយើងអាចត្រៀមលក្ខណៈប្រឆាំងបានភ្លាមៗ ដូច្នេះគឺមិនងាយចេញរោគសញ្ញាកូវីដ-19ទេ។ ប្រសិទ្ធភាពបង្ការការចេញរោគសញ្ញាចាប់ពីថ្ងៃទី7ក្រោយចាក់វ៉ាក់សាំងបាន២លើក ចំពោះក្មេងអាយុចាប់ពី 5-11 ឆ្នាំ ត្រូវបានរាយការណ៍ថាមានអត្រា 90.7% (*)។

(*) ទិន្នន័យមុនប្រភេទបំប្លែងថ្មីអូមីក្រុងលេចចេញ។

ប្រភព៖ យោងតាមរបាយការណ៍ពាក់ព័ន្ធនឹងការទទួលស្គាល់ក្នុងករណីពិសេស

## សុវត្ថិភាពនៃវ៉ាក់សាំងកូវីដ-19

### Q. ក្រោយកុមារបានចាក់វ៉ាក់សាំងកូវីដ-19 តើនឹងមានចេញអាការបែបណា?

**A. ភាគច្រើនបំផុតគឺមានការឈឺចាប់នៅត្រង់កន្លែងចាក់។**

នៅក្នុងរង្វង់ប៉ុន្មានថ្ងៃបន្ទាប់ពីចាក់វ៉ាក់សាំង អាការៈឈឺចាប់នៅត្រង់កន្លែងចាក់គឺមានកើតឡើងច្រើន (លើកទី1 មានអត្រា74% និងលើកទី2 មានអត្រា71%)។ អ្នកដែលមានអារម្មណ៍ឈឺចាប់នៅយប់នៃថ្ងៃចាក់ឬនៅថ្ងៃបន្ទាប់ មានច្រើនជាងក្រោយពេលចាក់ហើយភ្លាមៗ។ អាការៈអស់កម្លាំងឬក្តៅខ្លួន បន្ទាប់ពីចាក់លើកទី2គឺមានលេចចេញច្រើនជាងក្រោយពេលចាក់លើកទី1 (ក្តៅខ្លួន កម្រិត 38℃ឡើងទៅ, នៅពេលចាក់លើកទី1 មានអត្រា2.5% និងលើកទី2 មានអត្រា6.5%)។ អាការៈក្រោយពេលចាក់វ៉ាក់សាំង ស្ទើរតែទាំងស្រុងគឺមានកម្រិតស្រាល ឬកម្រិតមធ្យម ហើយតាមរយៈព័ត៌មានដែលទទួលបានត្រឹមពេលនេះ គេវិនិច្ឆ័យថាមិនមានការព្រួយបារម្ភធ្ងន់ធ្ងរអំពីសុវត្ថិភាពឡើយ។

**■អាការៈអាចកើតមានក្នុងរង្វង់ប៉ុន្មានថ្ងៃក្រោយចាក់**

| ភាគរយនៃអ្នកចេញអាការ | អាការ |
|---|---|
| 50% ឡើងទៅ | ឈឺចាប់ត្រង់កន្លែងចាក់ អារម្មណ៍អស់កម្លាំង |
| 10 -50% | ឈឺក្បាល ឡើងក្រហម/ហើមត្រង់កន្លែងចាក់ ឈឺសាច់ដុំ ស្រៀវស្រាញ |
| 1 -10% | រាករូស ក្តៅខ្លួន ឈឺសន្លាក់ ក្អួត |

ប្រភព៖ យោងតាមរបាយការណ៍ពាក់ព័ន្ធនឹងការទទួលស្គាល់ក្នុងករណីពិសេស

### Q. មានព័ត៌មានថា មនុស្សប្រុសវ័យកាន់តែក្មេងគឺកាន់តែងាយចេញអាការរលាកសាច់ដុំបេះដូង ចុះកូនក្មេងយ៉ាងម៉េចដែរ?

**A. នៅសហរដ្ឋអាមេរិកមានរបាយការណ៍អំពីកម្រិតនៃជំងឺរលាក់សាច់ដុំដែលបានកើតឡើងមានអត្រាទាបជាងសម្រាប់ក្មេងប្រុសដែលមានអាយុចន្លោះ 5-11ឆ្នាំ បើធៀបនឹងក្មេងអាយុចន្លោះ12-17ឆ្នាំ។**

ត្បិតជាករណីកម្រ នៅបរទេសក៏មានការរាយការណ៍ពីករណីចេញអាការរលាកសាច់ដុំបេះដូងកម្រិតស្រាលចំពោះកុមារផងដែរ។

នៅសហរដ្ឋអាមេរិច អត្រារាយការណ៍ថាលេចចេញរលាកសាច់ដុំបេះដូងក្រោយចាក់វ៉ាក់សាំងកូវីដ-19 ចំពោះក្មេងប្រុសអាយុ 5–11ឆ្នាំគឺទាបជាងក្មេងប្រុសអាយុ 12–15ឆ្នាំ និង16–17ឆ្នាំ។

ករណីឃើញកុមារមានអាការដូចជា ឈឺទ្រូង បេះដូងលោតខ្លាំង ដង្ហើមខ្លី អាការៈហើមជាដើមក្នុងចន្លោះពេលប្រហែល 4 ថ្ងៃក្រោយចាក់វ៉ាក់សាំង សូមរួសរាន់ទទួលការពិនិត្យពីស្ថាប័នវេជ្ជសាស្ត្រ នឹងប្រាប់ថាបានចាក់វ៉ាក់សាំង។

គួរបញ្ជាក់ថា បើត្រូវបានធ្វើរោគវិនិច្ឆ័យថាជាជម្ងឺរលាកសាច់ដុំបេះដូង ជាទូទៅត្រូវការសម្រាកព្យាបាលនៅមន្ទីរពេទ្យ ប៉ុន្តែភាគច្រើនគឺនឹងធូរស្រាលមកវិញដោយឯកឯងតាមរយៈការគេងសម្រាកនៅស្ងៀម។

ប្រភព៖ កិច្ចប្រជុំ ACIP ថ្ងៃទី5ខែមករាឆ្នាំ2022

# ដើម្បីចាក់វ៉ាក់សាំងកូវីដ-19

## ◎ដើម្បីចាក់វ៉ាក់សាំងលើកុមារ ចាំបាច់ត្រូវការការព្រមព្រៀងនិងវត្តមានរបស់អាណាព្យាបាល

នៅក្នុងការចាក់វ៉ាក់សាំង សូមធ្វើការសម្រេចចិត្តដោយផ្អែកលើឆន្ទៈរបស់អាណាព្យាបាលបន្ទាប់ពីបានស្វែងយល់ត្រឹមត្រូវទាំងអំពីប្រសិទ្ធភាពនិងហានិភ័យនៃផលរំខាននៃការចាក់វ៉ាក់សាំងការពារឆ្លង។ មិនមានការចាក់វ៉ាក់សាំងដោយគ្មានការព្រមព្រៀងពីអាណាព្យាបាលទេ។

ហាមឃាត់ចំពោះការបង្ខិតបង្ខំឲ្យអ្នកជុំវិញចាក់ ឬទង្វើរើសអើងចំពោះអ្នកដែលមិនបានចាក់។

## ◎នៅថ្ងៃចាក់វ៉ាក់សាំង សូមភ្ជាប់មកជាមួយនូវសៀវភៅសុខភាពមាតា និងទារក ប្រសិនបើអាច




ចំពោះការចាក់វ៉ាក់សាំងរបស់កុមារ ប្រវត្តិនៃការចាក់វ៉ាក់សាំងគឺត្រូវបានកត់ត្រានៅក្នុងសៀវភៅសុខភាពមាតា និងទារក ដូច្នេះនៅថ្ងៃចាក់ សូមភ្ជាប់មកជាមួយនូវសៀវភៅសុខភាពមាតានិងទារក ប្រសិនបើមាន។

ក្រៅពីនេះ សូមកុំភ្លេចភ្ជាប់ឯកសារមួយឈុតក្នុងស្រោមសំបុត្រដែលដាក់សេចក្តីជូនដំណឹងនេះ និងឯកសារបញ្ជាក់អត្តសញ្ញាណសាមីខ្លួន(ប័ណ្ណលេខសំគាល់អត្តសញ្ញាណ ប័ណ្ណធានារ៉ាប់រងសុខភាពជាដើម)។

## ◎បើមានចម្ងល់ឬការព្រួយបារម្ភអំពីវ៉ាក់សាំង សូមពិគ្រោះជាមួយគ្រូពេទ្យប្រចាំខ្លួនជាដើម

អំពីគម្លាតនៃការចាក់រវាងវ៉ាក់សាំងកូវីដ-19 នឹងវ៉ាក់សាំងប្រភេទផ្សេង សូមពិគ្រោះជាមួយគ្រូពេទ្យប្រចាំខ្លួន។ ជាគោលការណ៍គឺមិនអាចចាក់វ៉ាក់សាំងប្រភេទផ្សេងទៀតនៅពេលដំណាលគ្នា មុនឬក្រោយគ្នា ក្នុងអំឡុង២សប្តាហ៍ឡើយ។ ម្យ៉ាងទៀតករណីមានចម្ងល់ឬការព្រួយបារម្ភអំពីវ៉ាក់សាំង ក៏ដូចជាករណីកូនអ្នកមានជំងឺប្រចាំកាយផ្សេងៗ សូមពិគ្រោះជាមួយគ្រូពេទ្យប្រចាំខ្លួនឲ្យបានត្រឹមត្រូវ។

# កន្លែងពិគ្រោះយោបល់

## ◎កន្លែងពិគ្រោះយោបល់ពាក់ព័ន្ធនឹងវ៉ាក់សាំងកូវីដ-19

| | |
|---|---|
| **បើមានភាពមិនប្រក្រតីក្រោយចាក់វ៉ាក់សាំងរួច** ➡ | ស្ថាប័នវេជ្ជសាស្ត្រឬគ្រូពេទ្យប្រចាំខ្លួនដែលអ្នកបានទៅចាក់វ៉ាក់សាំង បញ្ជរការិយាល័យក្រុងស្រុកខណ្ឌឃុំសង្កាត់ភូមិឬរាជធានីខេត្ត |
| **ការសាកសួរព័ត៌មានពាក់ព័ន្ធការចាក់វ៉ាក់សាំងទាំងមូល** ➡ | បញ្ជរការិយាល័យក្រុងស្រុកខណ្ឌឃុំសង្កាត់ភូមិ |

## ◎អំពីប្រព័ន្ធជំនួយចំពោះការរងផលប៉ះពាល់សុខភាពដោយសារការចាក់វ៉ាក់សាំងបង្ការ

នៅក្នុងការចាក់វ៉ាក់សាំងបង្ការ អាចមានករណីកើតមានផលប៉ះពាល់សុខភាព(កើតជំងឺ ឬបន្សល់នូវពិការភាព)។ វាគឺកម្របំផុតប៉ុន្តែក៏មិនអាចបំបាត់ចោលទាំងស្រុងបានដែរ ហេតុនេះប្រព័ន្ធជំនួយត្រូវបានបង្កើតឡើង។

ចំពោះករណីកើតមានផលប៉ះពាល់សុខភាពដោយសារការចាក់វ៉ាក់សាំងបង្ការវីរុសកូវីដ-19នេះ គឺនឹងអាចទទួលបានជំនួយ(ការផ្តល់អត្ថប្រយោជន៍ចំណាយព្យាបាលនិងប្រាក់សោធននិវត្តន៍ពិការភាពជាដើម)ផ្អែកតាមច្បាប់ស្តីពីការចាក់វ៉ាក់សាំងបង្ការផងដែរ(*)។ ទាក់ទិនអំពីបែបបទដែលចាំបាច់ដើម្បីដាក់ពាក្យស្នើសុំ សូមប្រឹក្សាជាមួយរដ្ឋបាលក្រុងស្រុកខណ្ឌឃុំសង្កាត់ភូមិដែលមានសំបុត្រស្នាក់នៅរបស់អ្នក។

(*) ករណីផលប៉ះពាល់សុខភាពនោះត្រូវបានក្រសួងសុខាភិបាល ការងារនិងសុខុមាលភាពទទួលស្គាល់ថាបណ្តាលមកពីការចាក់វ៉ាក់សាំង ការផ្តល់អត្ថប្រយោជន៍នឹងត្រូវបានធ្វើឡើងតាមរយៈរដ្ឋបាលក្រុងស្រុកខណ្ឌឃុំសង្កាត់ភូមិ។ ការកំណត់ទទួលស្គាល់នេះ ត្រូវធ្វើឡើងដោយគណៈកម្មការត្រួតពិនិត្យទទួលស្គាល់ជំងឺនិងពិការភាពរបស់រដ្ឋ សិក្សាវិភាគហេតុ និងផល ដែលមានសមាសភាពដូចជាអ្នកជំនាញផ្នែកវ៉ាក់សាំងបង្ការ/ជំងឺឆ្លង/វេជ្ជសាស្ត្រ/ច្បាប់។

**អ្នកខ្លះក៏ទទួលបានការចាក់វ៉ាក់សាំងរួច ចំណែកអ្នកខ្លះក៏មិនបានចាក់វ៉ាក់សាំង។ ទោះបីទទួលបានការចាក់វ៉ាក់សាំងរួចហើយក្តី សូមបន្តអនុវត្តវិធានការបង្ការការឆ្លងដូចជា លាងដៃ/សម្លាប់មេរោគ ពាក់ម៉ាសឲ្យបានត្រឹមត្រូវ ដូចពេលកន្លងមក។**



**កន្លែងកកកុញ** / **ការប៉ះពាល់ជិតស្និទ្ធ** / **កន្លែងបិទជិត** / **ពាក់ម៉ាស** / **លាងដៃនឹងសាប៊ូ** / **សម្លាប់មេរោគម្រាមដៃ**

**សម្រាប់ព័ត៌មានលម្អិតអំពីប្រសិទ្ធភាពនិងសុវត្ថិភាពជាដើមនៃវ៉ាក់សាំងកូវីដ-19 ចំពោះកុមារ សូមមើលគេហទំព័រក្រសួងសុខាភិបាលការងារនិងសុខុមាលភាព។**

សុខាភិបាលការងារនិងសុខុមាលភាព វីរុសកូរ៉ូណា វ៉ាក់សាំង កុមារ | ស្វែងរក

ករណីមិនអាចមើលគេហទំព័រនេះបាន សូមប្រឹក្សាជាមួយរដ្ឋបាលក្រុងស្រុកខណ្ឌឃុំសង្កាត់ភូមិជាដើមដែលអ្នករស់នៅ។

(ថ្ងៃទី10 ខែកុម្ភៈ ឆ្នាំ2022)

厚生労働省
Ministry of Health, Labour and Welfare

## ចំពោះកុមារអាយុ 5-11 ឆ្នាំ



# សេចក្ដីជូនដំណឹងអំពីការចាក់វ៉ាក់សាំងការពារកូវីដ-19



## ហេតុអ្វីត្រូវចាក់វ៉ាក់សាំងកូវីដ?



បើមេរោគកូវីដចូលក្នុងខ្លួនមនុស្ស ហើយគ្នាវាកើនឡើងច្រើន វានឹងធ្វើឲ្យ ក្ដៅខ្លួន អស់កម្លាំង ក្អក ពិបាកដកដង្ហើម ឈឺក្បាល ប្រែប្រួលការភ្លក់ដឹងរសជាតិជាដើម ហើយនឹងធ្វើឲ្យមិនស្រួលខ្លួន។
បើចាក់វ៉ាក់សាំង ខ្លួនយើងនឹងអាចត្រៀមខ្លួនវាយជាមួយមេរោគកូវីដ ដូច្នេះ ទោះមេរោគឆ្លងចូលក្នុងខ្លួនក៏ដោយ ក៏មិនងាយធ្វើឲ្យទៅជាមិនស្រួលខ្លួនដែរ។

## ពេលចាក់វ៉ាក់សាំងកូវីដ តើគួរតែប្រយ័ត្ននឹងអ្វីខ្លះ?

| | |
|---|---|
| មុនចាក់ | បើក្ដៅខ្លួនចាប់ពី 37.5℃ ឡើងទៅ ឬបើមិនស្រួលខ្លួន គឺមិនអាចចាក់បានទេ ដូច្នេះសូមប្រាប់អ្នកផ្ទះ។ |
| ពេលចាក់ | វ៉ាក់សាំងនេះគឺចាក់នៅក្បែរស្មា។<br>សូមទៅចាក់ដោយពាក់អាវដែលងាយស្រួលលាត់ចេញស្មា។ |
| ក្រោយចាក់រួច | ◎ក្រោយចាក់វ៉ាក់សាំងរួច សូមអង្គុយចាំអោយបាន 15នាទីឡើងទៅ ដើម្បីតាមដានអាការៈផ្សេងៗ។ (ពេលខ្លះក៏អាចដល់ទៅ ៣០នាទីផងដែរ)<br>◎នៅថ្ងៃចាក់ អាចធ្វើសកម្មភាពដូចធម្មតាបាន ដូចជាងូតទឹកជាដើម ប៉ុន្តែសូមកុំហាត់ប្រាណខ្លាំង។<br>◎នៅពេលចាក់វ៉ាក់សាំង អាចនឹងចេញអាការៈមិនស្រួលខ្លួនដូចខាងក្រោម ប៉ុន្តែគេរកឃើញថាវានឹងបាត់ទៅវិញដោយខ្លួនឯងក្នុងពេល2–3ថ្ងៃ។<br>○ក្ដៅខ្លួន ○មិនស្រួលខ្លួន<br>○អស់កម្លាំង ○រាក<br>○ឈឺក្បាល ○រងាមិនស្រួលខ្លួន |











## បើមានអាការៈមិនស្រួលដូចខាងក្រោមនេះ សូមប្រាប់អ្នកផ្ទះឬមនុស្សធំដែលនៅជុំវិញ។

**●ពេលចាក់ហើយភ្លាម**

○រមាស់ខ្លួន
○ក្អក



**●នៅថ្ងៃចាក់ឬរយៈពេលប្រហែល4ថ្ងៃក្រោយចាក់ហើយ**

○ក្ដៅខ្លួន ○ឈឺក្បាល ○ឈឺទ្រូង ○ពិបាកដកដង្ហើម
○អស់កម្លាំង ○រងាមិនស្រួលខ្លួន ○ក្នុងទ្រូងឌុកឌាក់ៗ



## សូមចាក់វ៉ាក់សាំងនេះ 2លើក ដោយទុកគម្លាត 3 សប្ដាហ៍។



## រឿងសំខាន់ដែលចង់ឲ្យប្អូនៗធ្វើ។

មនុស្សមានផ្សេងៗគ្នា អ្នកខ្លះបានទទួលការចាក់វ៉ាក់សាំងបានលឿន ចំណែកអ្នកខ្លះក៏មានមូលហេតុផ្សេងៗដែលមិនអាចចាក់វ៉ាក់សាំងបានជាដើម។ សូមកុំយកហេតុផលនេះ ជាមូលហេតុក្នុងការនិយាយអាក្រក់ ឬធ្វើបាបអ្នកនៅជុំវិញជាដាច់ខាត។

